# វិធីសាស្ត្រគន្លឹះដើម្បីងាយស្រួលចូលមើល "ព័ត៌មានផ្ទាល់កំពុងជួញដូរ"

អេស៊ីលីដា ស៊ីឃ្យូរីធីភីអិលស៊ីបានផ្តល់ជម្រើសពិសេសជូនដល់អតិថិជន/វិនិយោគិនទាំងក្នុងនិងក្រៅប្រទេសអាចមើលនិងតាមដានព័ត៌មានផ្ទាល់កំពុងជួញដូររួមទាំងព័ត៌មាននិងទិន្នន័យពាក់ព័ន្ធក្នុងផ្សារមូលបត្រកម្ពុជាតាមរយៈទូរស័ព្ទដៃ, IPAD,Tablet, កុំព្យូទ័រ ជាដើមដែលមានភ្ជាប់អ៊ីនធឺណែត ។

## វិធីសាស្ត្រគន្លឹះ

1- អតិថិជននិងវិនិយោគិនមានគណនីជួញដូរជាមួយអេស៊ីលីដាស៊ីឃ្យូរីធី ។ ការបើកគណនីនៅអេស៊ីលីដាស៊ីឃ្យូរីធីគឺមិនគិតថ្លៃសេវាទេ។

2- ចុះឈ្មោះប្រើប្រាស់កម្មវិធី"**ព័ត៌មានផ្ទាល់កំពុងជួញដូរ**" (ដោយឥតគិតថ្លៃ) នៅអេស៊ីលីដាស៊ីឃ្យូរីធី។

3- ចូលទៅកាន់គេហទំព័រwww.acledasecurities.com.khរួចចុច ប៊ូតុង**ព័ត៌មានផ្ទាល់កំពុងជួញដូរ**




3-1. កម្មវិធី នឹងបង្ហាញផ្ទាំងដើម្បីវាយ**ឈ្មោះគណនី និងលេខសម្ងាត់** ដែលផ្តល់ដោយ អេស៊ីស៊ីដា ស៊ីឃ្យូរីធី រួចចុចប៊ូតុងLogin



3-2. បន្ទាប់មកកម្មវិធីនឹងបង្ហាញផ្ទាំងដូចខាងក្រោម:




**សេចក្តីពន្យល់នៃផ្ទាំងខាងលើនេះ**

**①ឈ្មោះភាគហ៊ុន**

ឈ្មោះភាគហ៊ុនបង្ហាញពីឈ្មោះជាអក្សរកាត់របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។ ក្នុងករណីមានក្រុមហ៊ុនបោះផ្សាយច្រើនអតិថិជន/វិនិយោគិនអាចធ្វើការជ្រើសរើសតាមតម្រូវការ ។

**②ព័ត៌មានថ្លៃទីផ្សារ**

. **ថ្លៃបច្ចុប្បន្ន**= 6,540 បង្ហាញថាថ្លៃជួញដូរបច្ចុប្បន្នស្មើនិង 6,540៛

. **ថ្លៃមូលដ្ឋាន**= 6,540 បង្ហាញថាថ្លៃបិទផ្សារនៃថ្ងៃដែលបានជួញដូរចុងក្រោយគឺស្មើ 6,540៛

. **ដែនកំណត់ថ្លៃខាងលើ**= 6,860 បង្ហាញថាថ្លៃមូលដ្ឋាន 6,540 x 1.05% = 6,860៛ [៩]
(អតិថិជន/វិនិយោគិនមិនអាចដាក់បញ្ជាលើសពីថ្លៃ 6,860 បានទេ)

. **ដែនកំណត់ថ្លៃខាងក្រោម**= 6,220 បង្ហាញថាថ្លៃមូលដ្ឋាន 6,540 x 95% = 6,220៛ [៩]
(អតិថិជន/វិនិយោគិនមិនអាចដាក់បញ្ជាទាបជាងពីថ្លៃ 6,220 បានទេ)

. **ថ្លៃបើក**= 6,520បង្ហាញថានៅវគ្គជួញដូរលើកទី១ ថ្លៃផ្គូផ្គងត្រូវគ្នាគឺស្មើ6,520៛

. **ថ្លៃខ្ពស់** = 6,540 បង្ហាញថានៅក្នុងវគ្គជួញដូរថ្លៃផ្គូផ្គងខ្ពស់ជាងគេគឺ 6,540៛

. **ថ្លៃទាប**= 6,520បង្ហាញថានៅក្នុងវគ្គជួញដូរថ្លៃផ្គូផ្គងទាបជាងគេគឺ 6,520៛

[៩] *ផ្សារមូលបត្រកម្ពុជាកំណត់ថ្លៃមូលដ្ឋានប្រចាំថ្ងៃត្រូវស្ថិតនៅចន្លោះ±5% ។*

### ③បញ្ជាបច្ចុប្បន្ន និងបរិមាណរំពឹងទុក

. **ថ្លៃរំពឹងទុក** បង្ហាញពីថ្លៃកំពុងជួញដូរដែលរំពឹងថានឹងអាចផ្គូផ្គងត្រូវគ្នានៅក្នុងវគ្គជួញដូរនីមួយៗ ។

. **បរិមាណរំពឹងទុក** បង្ហាញពីបរិមាណភាគហ៊ុនកំពុងជួញដូរដែលរំពឹងថានឹងអាចផ្គូផ្គងត្រូវគ្នានៅក្នុងវគ្គជួញដូរនីមួយៗ ។ នៅក្នុងប្រព័ន្ធ(កម្មវិធី)ព័ត៌មានផ្ទាល់កំពុងជួញដូរនេះធ្វើការបង្ហាញតែថ្លៃអាទិភាពជាងគេចំនួនប្រាំជួរប៉ុណ្ណោះចំពោះបរិមាណលក់នៅសល់ និងបរិមាណទិញនៅសល់។

. **បរិមាណលក់នៅសល់** បង្ហាញពីការដាក់សំណើបញ្ជាលក់របស់វិនិយោគិនដែលមិនទាន់ផ្គូផ្គងត្រូវគ្នា ។

- ភាគហ៊ុនលក់ចំនួន 35,703 ថ្លៃលក់ក្នុងមួយហ៊ុនគឺ 6,700៛
- ភាគហ៊ុនលក់ចំនួន100 ថ្លៃលក់ក្នុងមួយហ៊ុនគឺ 6,600៛
- ភាគហ៊ុនលក់ចំនួន 13,649 ថ្លៃលក់ក្នុងមួយហ៊ុនគឺ 6,560៛

. **បរិមាណទិញនៅសល់** បង្ហាញពីការដាក់សំណើបញ្ជាទិញរបស់វិនិយោគិនដែលមិនទាន់ផ្គូផ្គងត្រូវគ្នា ។

- ភាគហ៊ុនទិញចំនួន 8,371 ថ្លៃទិញក្នុងមួយហ៊ុនគឺ 6,540៛
- ភាគហ៊ុនទិញចំនួន 3,412 ថ្លៃទិញក្នុងមួយហ៊ុនគឺ 6,520៛
- ភាគហ៊ុនទិញចំនួន 35,000 ថ្លៃទិញក្នុងមួយហ៊ុនគឺ 6,500៛

***សម្គាល់:*** *អំពីគោលការណ៍ផ្គូផ្គងសំណើ*

- *ការជួញដូរត្រូវបានផ្គូផ្គងតាមរយៈការប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ និងវិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ។*
- *អាទិភាពនៃបញ្ជាទិញនិងបញ្ជាលក់៖*
  - ***១. អំពីថ្លៃ***
    - *បញ្ជាលក់ដែលមានថ្លៃទាបជាងមានអាទិភាពលើបញ្ជាលក់ដែលមានថ្លៃខ្ពស់ជាង។*
    - *បញ្ជាទិញដែលមានថ្លៃខ្ពស់ជាងមានអាទិភាពលើបញ្ជាទិញដែលមានថ្លៃទាបជាង។*
  - ***២. ពេលវេលា***
    - *សំណើបញ្ជាមានថ្លៃដូចគ្នាបញ្ជាដែលទទួលបានមុនមានអាទិភាពលើបញ្ជាដែលទទួលបានក្រោយ។*

### ④លទ្ធផលជួញដូរ

. **ថ្ងៃជួញដូរ** : ថ្ងៃច័ន្ទដល់ថ្ងៃសុក្រលើកលែងថ្ងៃឈប់សម្រាកជាសាធារណៈ។

. **ម៉ោងជួញដូរ** : ០៨:00ព្រឹកដល់ម៉ោង ១១:៣០ព្រឹក។

. **ការផ្គូផ្គង** :

- ម៉ោងជួញដូរពីម៉ោង ៨:00-៩:00 ព្រឹក ប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ដែលការផ្គូផ្គងនិងប្រព្រឹត្តទៅនៅម៉ោង ៩:00 ព្រឹក ។
- ម៉ោងជួញដូរពីម៉ោង ៩:00-១១:00 ព្រឹក ប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃច្រើន ដែលការផ្គូផ្គងត្រូវធ្វើឡើងភ្លាមៗនៅពេលបញ្ជាជួញដូរត្រូវគ្នា (វគ្គជួញដូរនិរន្តរ៍)
- ម៉ោងជួញដូរពីម៉ោង ១១:00-១១:៣០ ព្រឹក ប្រើប្រាស់វិធីសាស្ត្រដេញថ្លៃដោយយកថ្លៃតែមួយ ដែលការផ្គូផ្គងនិងប្រព្រឹត្តទៅនៅម៉ោង ១១:៣០ ព្រឹក

ឧទាហរណ៍៖សូមមើលការបង្ហាញនៅក្នុងរូបភាព



លទ្ធផលជួញដូរ

| ម៉ោង | ថ្លៃជួញដូរ | បម្រែបម្រួល | %បម្រែបម្រួល | បរិមាណជួញដូរ | តម្លៃជួញដូរ(រៀល) |
|---|---|---|---|---|---|
| 09:00AM | 6,520 | 20 | -0.31 | 3,260 | 21,255,200 |

នៅម៉ោង០៩:00AM ការផ្គូផ្គងមានចំនួន ៣,២៦០ ហ៊ុន តម្លៃក្នុងមួយហ៊ុនគឺ ៦,៥២០៛ ថ្លៃប្រែប្រួលធ្លាក់ចុះ ២០៛ ធៀបនិងថ្លៃម្សិលមិញ ហើយការប្រែប្រួលគិតជាភាគរយគឺ-0.៣១% និងការជួញដូរគិតជាទឹកប្រាក់គឺ ២១,២៥៥,២០០៛ ។

| | | | | | |
|---|---|---|---|---|---|
| 09:30AM | - | - | - | - | - |

នៅម៉ោង០៩:៣០AM ការផ្គូផ្គងមិនត្រូវគ្នា ដូច្នេះប្រព័ន្ធមិនមានទិន្នន័យសម្រាប់បង្ហាញទេ ។

| | | | | | |
|---|---|---|---|---|---|
| 10:00AM | 6,540 | 0 | 0 | 10,000 | 65,400,000 |

នៅម៉ោង ១០:00AMការផ្គូផ្គងមានចំនួន ១០,000 ហ៊ុន តម្លៃក្នុងមួយហ៊ុនគឺ ៦,៥៤០៛ ថ្លៃប្រែប្រួលគឺថេរ ធៀបនិងថ្លៃម្សិលមិញ ហើយការប្រែប្រួលគិតជាភាគរយគឺថេរ និងការជួញដូរគិតជាទឹកប្រាក់គឺ៦៥,៤00,000 ៛ ។

*អតិថិជន/វិនិយោគិនអាចមើលលទ្ធផលជួញដូរតាមរូបខាងលើរហូតដល់ម៉ោង១១:៣0AMដែលជាម៉ោងបិទផ្សារហ៊ុន ។*

## ⑤**ការបិទកម្មវិធី**

នៅពេលអតិថិជន/វិនិយោគិនឈប់តាមដានប្រព័ន្ធព័ត៌មានផ្ទាល់កំពុងជួញដូរនេះត្រូវធ្វើការចាកចេញពីកម្មវិធី ដោយចុចទៅលើឈ្មោះរបស់អតិថិជន/វិនិយោគិនដែលបង្ហាញជាភាសាអង់គ្លេសនៅខាងលើរួចចុចពាក្យថា ចាកចេញ ។ ក្នុងករណីមិនអនុវត្តតាមវិធីនេះ ប្រព័ន្ធនឹងធ្វើការបិទមិនឲ្យចូលរយៈពេល**១៥នាទី**ហើយផុតរយៈពេលនេះទើបអាចចូលប្រព័ន្ធសារឡើងវិញបាន ។

**អេស៊ីលីដា ស៊ីយូរីធី ផ្តល់ព័ត៌មានទាន់សម័យដើម្បីភាពជោគជ័យរបស់អតិថិជន!**